**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

លេខៈ ០៣៦០/២៤ ក.ប/អ.ក/អ.ធ.ក/ព.ក

**ជម្រាបមក**

**លោក ម្ចាស់ ឬនាយកក្រុមហ៊ុន ឡេក ស្ព័រ (ខេមបូឌា) អ៊ិនដាសស្ទ្រៀល**

**អ៊ិនវេសមិន ឌីវេឡុបមិន (វិស័យកាត់ដេរ)**

អាសយដ្ឋានៈ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

**យោង** ៖ លិខិតចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក ម្ចាស់ ឬនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២៦៥នាក់ (ស្រី ២០០នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ២៧១នាក់ (ស្រី ២០៥នាក់) គិតចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ។ ការផ្តល់ប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ អនុវត្តត្រឹមដំណាច់ ខែធ្នូ ឆ្នាំ២០២៣ លើកលែងតែមានសេចក្តីណែនាំថ្មីរបស់រាជរដ្ឋាភិបាល ដើម្បីបន្តអនុវត្តផ្តល់ប្រាក់ឧបត្ថម្ភ។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោក ម្ចាស់ ឬនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោក ម្ចាស់ ឬនាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ។

អាស្រ័យដូចនេះ សូម **លោក ម្ចាស់ ឬនាយក** បិទផ្សាយនូវលិខិតនេះជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោក ម្ចាស់ ឬនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ សុក្រ ៦ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

**ត.ប. រដ្ឋមន្ត្រី**

**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**ខេម ម៉ិនឈាន**

**ចម្លងជូនៈ**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋបាលរាជធានី ខេត្ត